អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# សួស្តីឆ្នាំថ្មី

# HAPPY KHMER NEW YEAR




សូមស្កេនQR Code

គំនូរជីវចល　　ធនធានបង្រៀន

Written by TukTuk

Illustrated by Choven Hen



ថ្ងៃនេះ រតនានិងមករាសប្បាយចិត្តខ្លាំងណាស់ ដោយសារវ៉ាកងតូចទើបចាប់ផ្តើម។
ថ្ងៃចូលឆ្នាំប្រពៃណីខ្មែរជិតមកដល់ហើយ ដូចនេះម្ដាក់ៗរវល់ណាស់ ព្រោះមានរបស់របរច្រើនត្រូវរៀបចំ។



នៅថ្ងៃចន្ទ រតនានិងមករាបានទៅទិញខោអាវនៅផ្សារជាមួយម្ដាយគាត់។
រតនាស្រឡាញ់រ៉ូបពណ៌ខៀវដ៏ស្រស់ស្អាតមួយ តែពេលនាងលទៅ រ៉ូបនោះបែរជាតូចពេក។
ដូច្នេះនាងក៏សាកលរ៉ូបពណ៌បៃតងវិញ តែវាបែរជាធំពេកទៅវិញ។
ចុងក្រោយនាងក៏សាករ៉ូបពណ៌លឿងមួយដែលត្រូវនឹងខ្លួននាងល្មមតែម្ដង។
ឯមករាវិញបានទិញខោពណ៌ក្រហមនិងអាវយឺតឆ្នូតមួយផងដែរ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C




នៅថ្ងៃអង្គារ មានសំឡេងស៊ីប្លេនៅក្រៅផ្ទះរបស់ក្មេងៗ។
ម្តាយរបស់ក្មេងទាំងពីរនិយាយ « ម៉ោះ! ថ្ងៃនេះយើងត្រូវទិញអីវ៉ាន់ច្រើនណាស់ »។ លោកគ្រូសុខកំពុងចាំពួកគេនៅលើរ៉ឺម៉កកង់បី។
សាកទាយមើលនរណាគេជាអ្នកបើករ៉ឺម៉កកង់បី? គឺយ៉េកនោះឯង! រតនានិងមករាសប្បាយចិត្តណាស់ដែលបានជួបយ៉េកម្តងទៀត។
លោកគ្រូសុខបានណែនាំយ៉េកឱ្យម្តាយក្មេងទាំងពីរបានស្គាល់។
រតនាសួរ « តើខេទីនៅឯណា? »
យ៉េកក៏ឆ្លើយ « មកពីមនុស្សច្រើនពេក ប្រហែលជិះមិនអស់ទេ ដូច្នេះនាងក៏ចាំនៅផ្ទះទៅ »។





ពេលទៅដល់ផ្សារ ពួកគេបានទិញភ្លើងលំអ ទាននិងធូបជាច្រើន។ យ៉េកសួរ « ទិញរបស់ទាំងនេះសម្រាប់ធ្វើអីហ្នឹង? » មករាឆ្លើយ « សម្រាប់អបអរថ្ងៃចូលឆ្នាំខ្មែរហ្នឹងណា »។ « ចុះស្បោងធំនោះវិញដាក់អីហ្នឹង? » តែលោកគ្រូសុខមិនឆ្លើយទេ បានត្រឹមញញឹម។ ម្តាយពួកគេក៏សួរទៅយ៉េក « យ៉េក! ចុះថ្ងៃបុណ្យចូលឆ្នាំខ្មែរនេះប្រុងធ្វើអ្វីដែរ? » យ៉េកឆ្លើយ « អត់មានគម្រោងថានឹងធ្វើអីផង »។ ម្តាយពួកគេនិយាយទៀត « អ៊ីចឹងអ្នកនិងខេទីអាចមកលេងពួកយើងបាន ហើយសឹមទៅវត្តទាំងអស់គ្នាតែម្តង »។ យ៉េកក៏ឆ្លើយ « បើអ៊ីចឹងមែនប្រសើរណាស់! អរគុណមីងច្រើនមែនទែន។ ចាំខ្ញុំដឹកអ្នកទាំងអស់គ្នាទៅតែម្តង »។ ឮដូចនេះ ក្មេងៗក៏ស្រែកហ៊ោដោយក្តីសប្បាយរីករាយ។



នៅថ្ងៃពុធ រតនានិងមករាជួយម្ដាយពួកគេសម្អាតផ្ទះ ខណៈពេលដែលគាត់នៅរវល់រៀបចំចម្អិនចំណីអាហារ។



រីឯថ្ងៃព្រហស្បតិ៍វិញ យ៉ោកនិងខេទីបានជិះរ៉ឺម៉កកង់បីមកដឹកអ្នកទាំងអស់គ្នាទៅផ្សារម្តងទៀត។



ម្តងនេះ ពួកគាត់ទិញតែផ្លែឈើប៉ុណ្ណោះ មានផ្លែម្នាស់ ក្រូច ស្វាយ ល្ហុង ចេកនិងផ្លែខ្នុរ។
យប់នោះ រតនានិងមករាសប្បាយចិត្តខ្លាំងសឹងតែដេកមិនលក់។



ជាចុងក្រោយ ថ្ងៃសុក្រដែលជាថ្ងៃចូលឆ្នាំទីមួយបានមកដល់។
យ៉េកនិងខេទីនាំគ្នាជិះរ៉ឺម៉កកង់បីមកជាមួយគ្នា ឯលោកគ្រូសុខបានដើរមកជួបជុំគ្នានៅផ្ទះរតនានិងមករា។
ខេទីលាន់មាត់ « អូ! តុបតែងបានស្អាតខ្លាំងណាស់ថ្ងៃនេះ »។
លោកគ្រូសុខក៏ប្រាប់យ៉េកនិងខេទី ថាថ្ងៃទីមួយនៃបុណ្យចូលឆ្នាំខ្មែរគេហៅថា ថ្ងៃមហាសង្ក្រាន្ត។
« នេះជាថ្ងៃដែលយើងទទួលស្វាគមន៍ទេវតាឆ្នាំថ្មី។ ផ្លែឈើ ទានធូបនិងភ្លើងលំអទាំងនេះជារណ្តាប់សម្រាប់ទទួលទេវតាឆ្នាំថ្មី
ដើម្បីឱ្យទ្រង់ប្រោសប្រណីការពារផ្ទះនិងក្រុមគ្រួសារយើង។ បន្ទាប់មក យើងនឹងទៅវត្តដើម្បីប្រគេនចង្ហាន់ជូនលោកសង្ឃផងដែរ »។



នៅលើរ៉ឺម៉កកង់បី មករាបានសួរខេទី « តើអ្នកចេះសំពះថ្វាយបង្គំលោកសង្ឃឬទេ? »
ខេទីប្រាប់ « ខ្ញុំមិនចេះទេ »។
មករាក៏ដាក់ដៃផ្ទឹមគ្នា ហើយលើកដៃសំពះដល់ថ្ងាសឱនចុះឱនឡើងចំនួន៣ដង។
គាត់ប្រាប់ខេទី « នេះហើយជារបៀបសំពះលោកសង្ឃ។ ខ្ញុំទើបរៀនចេះពីសាលាមត្តេយ្យមក! »



ថ្ងៃបន្ទាប់ជាថ្ងៃសៅរ៍ យ៉េកក៏បានមកដឹកអ្នកទាំងអស់គ្នាទៅវត្តម្តងទៀត។ ខេទីសួរលោកគ្រូសុខ « ថ្ងៃនេះជាថ្ងៃអ្វី? »
នេះជាថ្ងៃទីពីរនៃពិធីបុណ្យចូលឆ្នាំដែលឈ្មោះថា វិរៈវ័នបត។ ថ្ងៃនេះជាថ្ងៃដែលយើងរំលឹកដល់ដូនតាយើងដោយ
ប្រគេនចង្ហាន់ដល់លោកសង្ឃនិងឱ្យទានដល់អ្នកក្រខ្សត់។



ក្រោយពីបានប្រគេនចង្ហាន់លោករួចរាល់ហើយ រតនានិងមករាបានទៅអង្គុយកាយខ្សាច់។
ខេទីឆ្ងល់ក៏សួរ « តើអ្នកទាំងពីរកំពុងលេងដីមែនហ្នឹង? »
មករាឆ្លើយវិញ « មិនមែនទេ! យើងកំពុងពូនខ្សាច់ដើម្បីដាក់លើវាលុកចេតិយជាភ្នំខ្សាច់នៅទីនេះ។
ដំបូង យើងពូនចេតិយនៅកណ្ដាល ហើយបន្តពូនលើគ្រប់ចេតិយទាំងអស់ពីឆ្វេងទៅស្ដាំ។
យើងធ្វើអ៊ីចឹងគឺដើម្បីបួងសួងដល់ដូនតាយើងនិងសុំឱ្យគ្រួសារយើងមានសុខភាពល្អផងដែរ »។

អង្គការរុឺម៉កកង់បី
សម្រាប់កុមារ R4C



ថ្ងៃអាទិត្យជាថ្ងៃចុងក្រោយនៃពិធីបុណ្យចូលឆ្នាំដែលមានឈ្មោះថា វារៈឡើងស័ក។
នៅវត្ត គេនាំគ្នាយកទឹកទៅស្រង់ព្រះ។
រតនាប្រាប់ខេទី « ធ្វើអីចឹងគឺយើងលាងបាបដែលយើងបានសាងពីឆ្នាំមុន
ហើយវាក៏នាំសេចក្ដីសុខមកឱ្យយើងនៅឆ្នាំថ្មីនេះផងដែរ »។



ពេលទៅដល់ភូមិវិញ ដល់ពេលគេនាំគ្នាស្រង់ព្រះរស់ម្តង។
រតនានិងមករាក៏បានចូលជួយគេស្រង់ព្រះរស់នឹងគេផងដែរ។
រតនានិយាយ « ខ្ញុំសង្ឃឹមថាលោកតានឹងឱ្យដិបូន្នានល្អៗដល់ខ្ញុំដូចឆ្នាំមុនៗអីចឹង »។



ក្រោយពេលគេបានស្រង់ព្រះរស់ួចរាល់អស់ហើយនោះ ពួកគេក៏ញ៉ាំបាយជុំគ្នា។
ក្រោយពីញ៉ាំចប់សព្វគ្រប់ហើយនោះ លោកក្រួសុខក៏បានដើរលបៗទៅក្រៅបាត់...



« តើទាំងអស់គ្នារៀបចំខ្លួនហើយឬនៅ? » លោកគ្រូសុខនិយាយទាំងដៃមានកាន់ស្បោងខៀវធំមួយ។
« យេ៎! » ពួកក្មេងៗស្រែកហើយរត់ជុំវិញលោកគ្រូសុខ។
មករាស្រែកប្រាប់ឱ្យយ៉េកចូលទៅខាងប្រុស។ រតនាក៏ប្រាប់ឱ្យខេទីចូលជួយខាងស្រី។
យ៉េកឆ្ងល់ក៏សួរ « គេកំពុងធ្វើអីហ្នឹង? »
លោកគ្រូសុខក៏ឆ្លើយ « ដល់ពេលលេងល្បែងប្រជាប្រិយខ្មែរយើងហើយ! »



ដំបូង ពួកគាត់លេងល្បែងចោលឈូង



បោះអង្គុញ



និងស្វាដណ្ដើមស្លឹកឈើសិន។
ក្រុមខាងស្រីស្រែកហ៊ោកញ្ជ្រៀវ ដោយសារក្រុមខាងប្រុសៗចាញ់ ហើយត្រូវច្រៀងនិងរាំជាពិន័យ។



បន្ទាប់មកលោកគ្រូសុខបានប្រាប់ទាំងអស់គ្នាឱ្យអង្គុយជារង្វង់។
ម្នាក់ៗក៏ធ្វើតាមសំដីគាត់ ហើយពួកគេក៏ចាប់ផ្ដើមលេងល្បែងលាក់កន្សែង។
ក្មេងៗចូលចិត្តដេញចាប់យ៉េកនិងខេទីណាស់។




« បាទ! ដល់ពេលយើងលេងទាញព្រ័ត្រហើយ! »
« យ៉េ! » ម្នាក់ៗហក់ឡើងឈរ ហើយតម្រង់ជួរ។
« ១ ២ ៣ ចាប់ផ្ដើម! » យ៉េកក៏ចូលជួរជាមួយក្រុមប្រុសៗ។



តែពេលនោះ ក្រុមខាងស្រីៗក៏នាំគ្នាស្រែកថា « អយុត្តិធម៌ណាស់! យ៉េកមានកម្លាំងស្មើមនុស្សដប់នាក់ទៅហើយហ្នឹង! »
លោកគ្រូសុខក៏ដោះស្រាយ « មិនអីទេៗ! ម្តងនេះ ពីរនាក់ខ្ញុំនិងយ៉េកនឹងទាញជាមួយអ្នកទាំងអស់គ្នាក៏បាន »។
« យេ៎! » ក្មេងៗនាំគ្នាស្រែកសប្បាយរីករាយ។




យ៉េកក៏លាន់មាត់ « ពិធីបុណ្យចូលឆ្នាំខ្មែរពិតជាសប្បាយពិតមែន! រីករាយថ្ងៃបុណ្យចូលឆ្នាំថ្មីទាំងអស់គ្នា! »។
ក្មេងៗក៏ស្រែកតប « រីករាយថ្ងៃបុណ្យចូលឆ្នាំថ្មី! »។
ខេទីក៏ស្រែកសួរពីក្រោយ « រៀបចំខ្លួនហើយឬនៅទាំងអស់គ្នា? ១ ២ ៣ ចាប់ផ្តើម! »៕